**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០២២/១០ កប.ស.ជ.ណ

# សេចក្តីជូនដំណឹង

គណៈកម្មធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមជូនដំណឹងដល់មាតាបិតា អាណាព្យាបាល និងបងប្អូនដែលបានប្រលងជាប់តេស្តភាសាកូរ៉េលើកទី៣ ទី៤ និងទី៥កន្លងទៅឱ្យបានជ្រាបថា និយោជកកូរ៉េ (ថៅកែកូរ៉េ) បានចាប់ផ្តើមជ្រើសរើសពលករ-ពលការិនីកម្ពុជាសម្រាប់កូតាឆ្នាំ២០១០នេះហើយ ហេតុដូច្នេះសូមមាតាបិតា អាណាព្យាបាល និងបងប្អូនដែលបានប្រលងជាប់តេស្តភាសាកូរ៉េលើកទី៣ ទី៤ និងទី៥ ជ្រាបពីព័ត៌មាននេះ និងត្រូវបង្កើនការប្រុងប្រយ័ត្នអោយបានខ្ពស់ចៀសវាងការឆបោកពីសំណាក់ជនខិលខូចដែលអាចប្រើល្បិចធ្វើជាអ្នកធានាជួយបងប្អូនឱ្យបានទៅធ្វើការងារនៅសាធារណៈរដ្ឋកូរ៉េតាមវិធីផ្សេងៗឱ្យសោះ ។ តាមនីតិវិធី និងច្បាប់នៃការជ្រើសរើសពលករបរទេសនៃសាធារណៈរដ្ឋកូរ៉េកុំថាឡើយមន្ត្រីនៃគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស សូម្បីតែនិយោជកកូរ៉េ (ថៅកែកូរ៉េ) ក៏មិនអាចចង្អុលឱ្យចំៗពលករណាមួយឱ្យបានទៅធ្វើការងារនៅសាធារណកូរ៉េដែរ ព្រោះគ្រប់ពលករគឺត្រូវបានបញ្ចេញដោយប្រព័ន្ធកុំព្យូទ័រនៃក្រសួងការងារកូរ៉េតាមវិធីសាស្ត្រទំនើបទាំងអស់ ។

សារជាថ្មីម្តងទៀតគណៈកម្មាធិការសូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ការបញ្ជូនពលករ-ពលការិនីទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េនេះមានគឺមានតែគណៈកម្មាធិការមួយគត់ដែលមានសិទ្ធិសហការជ្រើសរើស និងបញ្ជូន ហើយមកដល់ពេលបច្ចុប្បន្ននេះគណៈកម្មាធិការក៏មិនដែលបានផ្តល់សិទ្ធិដល់បុគ្គល ឬក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាលភាសាបរទេសដែលមានបង្រៀនភាសាកូរ៉េណាមួយឱ្យជ្រើសរើស និងបញ្ជូនពលករទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េឡើយ ។

អាស្រ័យហេតុនេះ ក្នុងករណីដែលបងប្អូនសាធារណៈជនទទួលបានព័ត៌មានណាមួយដែលផ្ទុយពីគោលការណ៍ខាងលើសូមបងរួសរាន់ឃាត់ខ្លួន និងប្រមូលភស្តុតាងនានាប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងកើតហេតុ (ប៉ុស្តិ៍នគរបាលមូលដ្ឋាន) ជាបន្ទាន់ព្រោះវាជាអំពើល្មើសច្បាប់ ។ ដូចគ្នាផងដែរ ក្នុងករណីដែលបងប្អូនទទួលបានព័ត៌មានណាមួយដែលគួរឱ្យសង្ស័យសូមទំនាក់ទំនងមកគណៈកម្មាធិការតាមរយៈទូរស័ព្ទលេខ ០២៣-៦៥២ ៥៧៧៧ / ០១២-២១៤ ៧០១ / ០១១-៣៨៣ ៧៣៥ /០១៥-៦០៧ ៧១៧ នៅរៀងរាល់ម៉ោងធ្វើការដើម្បីសាកសួរបន្ថែម ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០*

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការ**

**បណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស**

**ពេជ សោភ័ន**

**<u>ចម្លងជូន:</u>**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវឧបនាយរដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងព័ត៌មាន
- គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
- គ្រប់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត “ដើម្បីសហការអនុវត្ត”
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ “ដើម្បីអនុវត្ត”
- ឯកសារកាលវប្បត្តិ